# សទ្ធា និង បញ្ញា



រៀបរៀងដោយ ភិក្ខុ ឌិច សេរី

# អំពីធម៌ពីរប្រការគឺ :
# សទ្ធា និង បញ្ញា
# លំនាំធម៌ទេសនា

**នមោ តស្ស ភគវតោ អរហតោ សម្មា សម្ពុទ្ធស្ស**

ខ្ញុំព្រះករុណាសូមនមស្ការ ចំពោះព្រះភគវន្តមុនី អរហន្តសម្មា សម្ពុទ្ធព្រះអង្គនោះ ព្រមទាំងព្រះធម៌ និង ព្រះអរិយសង្ឃ ដោយគោរព ។

លំដាប់អំពីបទនមស្ការនោះទៅ នឹងសូមដកស្រង់យកធម៌ ២ ប្រការគឺ : **សទ្ធា ១ , បញ្ញា ១ ,** មកអធិប្បាយដោយសង្ខេបដូចតទៅនេះ :

បើបុរស ស្ត្រីណាមានទ្រព្យពីប្រការគឺ : **សទ្ធា** នឹង **បញ្ញា** នេះ អ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាដើម លោកពោលថា បុរស ស្ត្រី នោះមិនមែនជាអ្នកទ័លក្រឡើយ គឺ ឈ្មោះថា អ្នកមានទ្រព្យសម្បត្តិដ៏ស្តុកស្តម្ភមាំមួនដោយពិត ទាំងការរស់នៅរបស់បុរស ស្ត្រីនោះទៀតក៏មិនមានឈ្មោះថា រស់នៅឥតអំពើឡើយ គឺថាជាអ្នករស់នៅដ៏ប្រសើរថ្លៃថ្នូរបំផុតក្នុងលោក ។ សមដូចពុទ្ធភាសិត ដែលស្រង់សំដែងទុកក្នុងគម្ពីរសំយុត្តនិកាយថា :

**សទ្ធីធ វិត្តំ បុរិសស្ស សេដ្ឋំ**
**បញ្ញាជីវី ជីវិតមាហុ សេដ្ឋំ**

"សទ្ធាជាទ្រព្យដ៏ប្រសើរបំផុតរបស់បុរសស្ត្រីក្នុងលោកនេះ " អ្នកប្រាជ្ញហៅបុគ្គលដែលរស់នៅដោយប្រាជ្ញាថាជាអ្នករស់នៅប្រសើរបំផុត ។

ចំណែកធម៌ទាំងពីរប្រការគឺ : **សទ្ធា** នឹង **បញ្ញា** នេះលោកទុកជាទ្រព្យដ៏ប្រសើរបំផុត របស់បុរស ស្ត្រីទូទៅជាងទ្រព្យក្នុងលោកទាំងអស់ ។ ទ្រព្យក្នុងលោកបើរួបរួមទៅឃើញថាមាន ២ ប្រការគឺ :

**១-សវិញ្ញាណកៈ** - ទ្រព្យដែលមានវិញ្ញាណដូចយ៉ាងបុត្រធីតា ខ្ញុំកំដរប្រុស , ស្រី , គោ , ក្របី , ដំរី , សេះ , ជ្រូក , មាន់ , ទា ជាដើម ។

**២-អវិញ្ញាណកៈ** - ទ្រព្យដែលគ្មានវិញ្ញាណ មាន ផ្ទះសម្បែង , មាស , ប្រាក់ ,កែវ , កង ,ពិទូរ្យសូរ្យកាន្ត , ស្រែចំការ ,អាហារ ,ច្បារដំណាំ ជាដើម។

ទ្រព្យទាំងពីរប្រការនេះ គ្រាន់តែជាទ្រព្យជួយឧបត្ថម្ភគាំទ្រមនុស្សក្នុងលោក ឱ្យបានសេចក្តីសុខ - ចំរើនតែក្នុងបច្ចុប្បន្នជាតិគឺក្នុងជាតិដែលកំពុងរស់នៅប៉ុណ្ណោះទេ , លោកមិនរាប់ថាជាទ្រព្យដ៏ប្រសើរបានឡើយ , ព្រោះថាទ្រព្យទាំងនេះមិនអាចនឹងកាន់យកទៅជាមួយ ក្នុងពេលដែលខ្លួនលះលោកនេះទៅកាន់លោកខាងមុខបានឡើយ ។

សមដូចពុទ្ធភាសិតថា

**" សព្វំ បហាយ គមនីយំ "**

សត្វលោកគឺពពួកសត្វសុទ្ធតែត្រូវលះបង់នូវវត្ថុទាំងពួង ហើយទៅទាំងរាងកាយទៀតសោត ក៏ត្រូវលះបង់ចោលនៅផែនដី ដូចជាអង្កត់ឧសរក

ប្រយោជន៍ គ្មានដែរ , របស់ដែលត្រូវយកទៅជាមួយនឹងខ្លួនបាននោះ មានតែទ្រព្យពីរប្រការគឺ : **សទ្ធា** នឹង **បញ្ញា** ដែលជាទ្រព្យប្រសើរបំផុតនោះទើបអាចកាន់យកទៅបាន ក្នុងពេលដែលខ្លួនលះលោកនេះ ទៅកាន់លោកខាងមុខ បានដោយពិតប្រាកដមែន ។

**ឆ ១- សទ្ធា :** ការជឿចំពោះហេតុណាដែលគួរជឿដោយពិត ទើបចាត់ថាជាទ្រព្យដ៏ប្រសើរទៅបាន , បើគ្រាន់តែជឿៗទៅមិនពិនិត្យរកហេតុផលផងក៏មិនឱ្យឈ្មោះថា **សទ្ធា** ក្នុងទីនេះដែរ , **សទ្ធា** ក្នុងទីនេះ បើចែកតាមប្រភេទមាន ៤ ប្រការគឺ :

១- **កម្មស្សទ្ធា** - ការជឿកម្ម គឺជាកម្មជាកុសល មានការឱ្យទានរក្សាសីលចំរើនមេត្តាភាវនាជាដើម ជាហេតុនាមឱ្យកើតសេចក្តីសុខ ឬនឹងហៅថាជាកំណើតរបស់សេចក្តីសុខដូច្នេះវិញក៏បាន ។

ម្យ៉ាងទៀតជឿកម្មជាអកុសល មានការប្រព្រឹត្តអាក្រក់ ដោយកាយវាចាចិត្តជាដើម ជាហេតុនាំឱ្យកើតទុក្ខទោសក្នុងលោកនេះនឹងលោកខាងមុខដោយជាក់ស្តែង ។ ការជឿចំពោះកម្មជាកុសល នឹង កម្មជាអកុសលថាបានសុខបានទុក្ខអាស្រ័យមកពីកម្មប៉ណ្ណោះឯងហៅថា **កម្មស្សទ្ធា** ។

២- **វិបាកស្សទ្ធា** - ការជឿផលគឺជឿថាបុគ្គលដែលបានសេចក្តីសុខ - ចំរើនក៏សុទ្ធតែជាផលនៃកុសល ដែលខ្លួនបានសាងសន្សំទុកមកអំពីខាងដើមហើយអាចញ៉ែកមុខឱ្យផលបានសុខតាមលំដាប់តាមថ្នាក់ , អ្នកណាដែលមានសេចក្តីវិនាសសាបសូន្យ ចាកផលប្រយោជន៍គ្រប់យ៉ាង ក៏សុទ្ធតែជាផល នៃអកុសល ឬថាជាផលនៃបមាទធម៌គឺសេចក្តីធ្វេសប្រហែសក្នុងខ្លួនជានិច្ច ! ដូចគ្នានឹងពូជដំណាំដែលបុគ្គលក្នុងលោកសាបព្រួសបណ្តុះដាំយ៉ាងណា ? មុខជានឹងបានផ្លែផ្កាមកយ៉ាងនោះវិញ ។ ការជឿផលនៃកម្មថាបានសុខបានទុក្ខអាស្រ័យមកពីផលរបស់កម្មប៉ណ្ណោះឯងហៅថា វិបាកស្សទ្ធា ។

៣- **កម្មស្សកតាសទ្ធា** : ការជឿថាសត្វមានកម្មជារបស់ខ្លួន គឺជឿថាសព្វសត្វទាំងអស់បានទទួលសេចក្តីសុខ - ទុក្ខទាំងបច្ចុប្បន្ន នឹងក្នុងកាលទៅអនាគត ក៏សុទ្ធតែជាប់ទាក់ទងដោយកម្មទាំងអស់ ។ កម្មនេះឱ្យផលផ្សេងៗគ្នាមាន ៧ យ៉ាង គឺ :

| | |
|---|---|
| ១- មានអាយុវែង | ព្រោះមិនសម្លាប់សត្វ |
| ២- មិនមានរោគ | ព្រោះមិនបៀតបៀនសត្វ |
| ៣- មានសម្បុរល្អ | ព្រោះមិនគ្រោធខឹង |
| ៤- មានគេជានុភាពច្រើន | ព្រោះមិនច្រណែនឈ្នានីសគេ |
| ៥- មានទ្រព្យសម្បត្តិច្រើន | ព្រោះបរិច្ចាគទាន |
| ៦- មានត្រកូលខ្ពង់ខ្ពស់ | ព្រោះគោរពកោតក្រែងចំពោះចាស់ព្រឹទ្ធាចារ្យ |
| ៧- មានប្រាជ្ញា | ព្រោះសេពគប់នឹងសប្បុរស ។ |

ការជឿថាសត្វកើតឡើងសុទ្ធតែជាប់ទាក់ទងដោយកម្មទាំងអស់ សមនឹងពុទ្ធភាសិតសំដែងថា :

**កម្មស្សកោម្ហិ កម្មទាយាទោ កម្មយោនិ**
**កម្មពន្ធុ កម្មប្ប- ដិសរណោ យំ កម្មំ ករិស្សាមិ**
**កល្យាណំ វា ចាមកំ វា តស្សទាយាទោ ភវិស្សាមិ ។**

អាត្មាអញមានកម្មជារបស់ខ្លួន មានកម្មជាអ្នកឱ្យផល , មានកម្មជាកំណើត , មានកម្មជាផៅពង្ស , មានកម្មជាទីពុំនាក់អាស្រ័យ , អាត្មាអញនឹងធ្វើកម្មណា ជាកម្មល្អក្តី អាក្រក់ក្តី អាត្មាអញនឹងត្រូវជាអ្នកទទួលនូវផលនៃកម្មនោះពុំខាន ។

ការជឿប៉ុណ្ណេះហៅថា **កម្មស្សកតាសទ្ធា** ។

៤- **តថាគតពោធិស្សទ្ធា** : ការជឿប្រាជ្ញាក្នុងការត្រាស់ដឹងរបស់ព្រះតថាគត , គឺជឿថាព្រះអង្គត្រាស់ដឹងនូវធម៌ពិត ឥតមានគ្រូអាចារ្យណាមកប្រដៅព្រះអង្គឡើយ , ឯធម៌ពិតនោះគឺ បានដល់អរិយសច្ចធម៌ទាំង ៤ ប្រការគឺ : **ទុក្ខសច្ចះ** ១ , **សមុទយសច្ចះ** ១ , **និរោធសច្ចះ** ១ , **មគ្គសច្ចះ** ១ ។

**ទុក្ខសច្ចះ** នោះបានដល់ជាតិ , ជរា , ព្យាធិ , មរណៈ , ដែលជាសភាវៈនាំមកនូវទុក្ខដោយពិតប្រាកដ ។

**សមុទយសច្ចះ** នោះបានដល់តណ្ហា គឺសេចក្តីប្រាថ្នា , ការចង់បាន , សេចក្តីអន្ទះអន្ទែងបំរះនន្ទៀល , បើពោលដោយសង្ខេបមាន ៣ យ៉ាង គឺ : កាមតណ្ហាសេចក្តីចំណង់ក្នុងកាមមួយ , ភវតណ្ហាសេចក្តីចំណង់ក្នុងភពមួយ , វិភវតណ្ហាសេចក្តីចំណង់ក្នុងអរូបភពមួយ , បើពោលដោយពិស្តារមានដល់ ១០៨ គឺទៅតាមឈ្មោះអារម្មណ៏ទាំង ៦ គឺ : រូបតណ្ហា ១ , សទ្ទតណ្ហា ១ , គន្ធតណ្ហា ១ , រសតណ្ហា ១ , ផោដ្ឋព្វតណ្ហា ១ , ធម្មតណ្ហា ១ , ដូចជាកូនគេដាក់ឈ្មោះតាមបិតាថា " សេដ្ឋិបុត្រ " " ព្រម្មណបុត្រ " ប៉ុណ្ណោះជាដើម ។ បណ្តាតណ្ហាទាំង ៦ នេះ តណ្ហាមួយៗ មានឈ្មោះបីៗទៀត គឺតណ្ហាបីខាងលើហ្នឹងឯង ។ ប្រាំមួយបីដងត្រូវជាដប់ប្រាំបី ( ១៨ ) ។ចែកតណ្ហាដែលប្រព្រឹត្តទៅខាងក្នុង ១៨ ខាងក្រៅ ១៨ ទៀត ពីរដងត្រូវជា ៣៦ ។ ចែកជាអតីត ៣៦ - អនាគត ៣៦ , បច្ចុប្បន្ន ៣៦ ទៀតត្រូវជា ១០៨ ។ ទាំងនេះសុទ្ធតែជាមេកិលេស បណ្តាលនាំឱ្យកើតទុក្ខតទៅ ។

**និរោធសច្ចះ** នោះបានដល់ព្រះនិព្វាន ជាទីរំលត់បង់នូវទុក្ខទាំងពួង , ពីព្រោះពាក្យថា " ព្រះនិព្វាន "នេះប្រែថាព្រះធម៌រំលត់នូងកិលេស , រំលត់នូវបញ្ចក្ខន្ធ , គឺលោកុត្តរធម៌ទី ៩ ដែលកើតមកអំពី លោកុត្តរធម៌ទាំង ៨ ខាងដើម ( មគ្គ ៤ , ផល ៤ ) ព្រោះព្រះនិព្វាននេះទៀងទាត់ប្រាកដគ្រប់យ៉ាង គឺមិនចេះត្រឡប់វិលវល់កើតចាស់ ឈឺស្លាប់ មិនស្តាប់បង្គាប់តណ្ហាមិនលុះក្នុងអំណាចរបស់អវិជ្ជា មានតែសេចក្តីសុខម្យ៉ាងដែលហៅថា " ឯកន្តបរមសុខ "

សុខយ៉ាងក្រៃលែងឥតមានគូប្រដូច , សុខដ៏ក្រៃលែងដោយចំណែកមួយទៀងទាត់ពិតប្រាកដ មិនវិលត្រឡប់ប្រែក្លាយជាទុក្ខវិញឡើយ ព្រោះកមចាត់បង់នូវឫសគល់នៃសេចក្ដីទុក្ខអស់រលីង ឥតមានសេសសល់បន្តិចបន្តួច មានតែព្រះនិព្វានប៉ុណ្ណោះឯង ។

**មគ្គសច្ចៈ** នោះបានដល់ផ្លូវអដ្ឋង្គិកមគ្គទាំង ៨ ប្រការ មានសម្មាទិដ្ឋិ ប្រាជ្ញាយល់ឃើញត្រូវជាដើម ។ល។ នឹងសម្មាសមាធិ កិរិយាដំកល់ចិត្តឱ្យនឹងត្រូវជាទីបំផុត , នេះជាផ្លូវអដ្ឋង្គិកមគ្គទាំង ៨ ប្រការ ដែលជាដំណើររបស់ព្រះអរិយបុគ្គលទាំងឡាយមានព្រះពុទ្ធជាដើម ព្រះអង្គបានដើរសុខស្រួលហើយចង្អុលប្រាប់ពុទ្ធបរិស័ទទាំងឡាយថា អ្នកទាំងឡាយនេះជាផ្លូវសម្រាប់ដើរឱ្យរំងាប់ទុក្ខទៅបាន , បើដឹងដូច្នេះហើយត្រូវតែខំព្យាយាមដើរទើបអាចរំងាប់នូវទុក្ខបាន , សមដូចជាព្រះពុទ្ធដីកាទ្រង់សំដែងថា : **វីរិយេន ទុក្ខមច្ចេតិ** " សត្វ ឆ្លងនូវសេចក្ដីទុក្ខលំបាកបាន ដោយសារសេចក្ដីព្យាយាម " ការជឿចំពោះសម្មា សម្ពោធិញាណរបស់ព្រះតថាគត នឹងធម៌របស់ព្រះអង្គ ដែលទ្រង់សំដែងទុកមក ដោយប្រពៃមានបទថា " **ស្វាក្ខាតោ ភគវតោ ធម្មោ** " ប៉ុណ្ណោះជាដើម ព្រមទាំងព្រះសង្ឃជាសាវ័ករបស់ព្រះអង្គ ដែលប្រតិបត្តិហើយ ដោយប្រពៃ មានបទថា " **សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ** " ប៉ុណ្ណោះជាដើម ។

ការជឿយ៉ាងនេះហៅថា តថាគតពោធិសទ្ធា ។

បុរស ស្ត្រីឯណាមានសទ្ធា គឺការជឿចំពោះហេតុផលដែលគួរជឿប៉ុណ្ណោះ លោកទុកថាជាអ្នកមានស្បៀង គឺកុសលសម្រាប់ផ្លូវ ទៅកាន់បរលោកបានដោយពិត ។ សមនឹងពុទ្ធភាសិតថា : **សទ្ធា ពន្ធតិ បាថេយ្យំ** " សទ្ធា រួបរួមទុកនូវស្បៀង គឺកុសល " សទ្ធាកាលណាបើកើតមានហើយក៏អាចឱ្យ បំពេញទាន រក្សាសីល ចំរើនមេត្តា ភាវនា ដែលជាចំណែកកុសលសុទ្ធ ហើយក៏បានសោយនូវសម្បត្តិទាំង ៣ ប្រការគឺ : សម្បត្តិមនុស្ស ១ , សម្បត្តិទេវតា ១ , សម្បត្តិព្រះនិព្វាន ១ , បើសទ្ធាមិនកើតឡើងទេ បុណ្យ កុសលដទៃៗ ក៏មិនអាចកើតឡើងបានដែរ , ធម្មតាបុគ្គលក្នុងលោកអ្នកតាំង ចិត្តនឹងចេញដើរទៅកាន់ផ្លូវឆ្ងាយដាច់ស្រយាលនោះ សុទ្ធតែត្រូវរៀបចំស្បៀង អាហារសម្រាប់តាមផ្លូវរហូតទាល់តែដល់ស្រុកទេសដែលបំរុងនឹងទៅនោះយ៉ាងណា បុគ្គលអ្នកមានសទ្ធា ក៏ត្រូវតែរៀបចំស្បៀងគឺកុសលដែលបំរុងនឹងទៅ កាន់បរលោកក៏យ៉ាងនោះដែរ ។

ម្យ៉ាងវិញទៀតសទ្ធានេះឯង ក៏អាចធ្វើឱ្យសត្វឱ្យឆ្លងនូវអន្លង់បានសមដូចពុទ្ធភាសិតថា : **សទ្ធាយ តរតិ ឱឃំ** " សត្វឆ្លងអន្លង់បានដោយសារសទ្ធា " តាមទំនៀមមកថា អ្នកស្រុកអ្នកប្រទេសដែលគេតែងឆ្លង ស្ទឹង ទន្លេ , ឬសមុទ្រ ជាដើមនោះ , សុទ្ធតែគេត្រូវស្វែងរកនាវាតូច ធំ ទើបនឹងអាចឆ្លងស្ទឹង ទន្លេ ឬ សមុទ្រជាដើមនោះបាន , បើវៀរតែរបស់ប៉ុណ្ណោះហើយក៏មិនអាចនឹងឆ្លងបានឡើយ ឯក្នុងទីនេះ ព្រះបរមគ្រូជាម្ចាស់ទ្រង់ត្រាស់ថា

សត្វឆ្លងអន្លង់បានដោយសារសទ្ធាទៅវិញ , សភាពមួយយ៉ាងដែលធ្វើចិត្តរបស់សត្វឱ្យលិចលង់ ក្នុងកាមគុណទាំង ៥ ប្រការ នាំឱ្យភ្លេចទាំងកុសលធម៌ ធ្វើសត្វមិនឱ្យឆ្លងចាកសមុទ្រគឺសង្សារបាន , សភាពយ៉ាងនេះឯងហៅថា ឱឃៈដូចជាជំនន់ទឹក ព្រោះលិចសង្កត់ចិត្តរបស់សត្វគ្រប់រូប , ឯ ឱឃៈនោះមាន ៤ ប្រការ គឺ : កាមោឃៈជំនន់គឺកាម ១ , ភវោឃៈ ជំនន់គឺភព ១ , ទិដ្ឋោឃៈ ជំនន់ គឺសេចក្ដីយល់ឃើញ ១ , អវិជ្ជោឃៈ ជំនន់គឺអវិជ្ជា ១ , ជំនន់ទាំង ៤ ប្រការនេះនឹងយកទូក សំពៅជាដើមទៅឆ្លងមិនរួចឡើយ , លុះតែយកសទ្ធាទៅធ្វើជាទូក ឬសំពៅ ទើបនឹងអាចឆ្លងបាន , ក៏ឯសទ្ធាក្នុងបទនេះសំដៅយកសទ្ធា ២ ប្រការគឺ **បសាទនលក្ខណសទ្ធា** សទ្ធាដែលមានសេចក្ដីជ្រះថ្លាជាលក្ខណៈ ១ , **បក្ខន្ទនលក្ខណសទ្ធា** សទ្ធាដែលមានកិរិយាស្ទុះទៅជាលក្ខណៈ ១, សទ្ធាទាំង ២ ប្រការនេះហើយដែលសម្រាប់ឆ្លងជំនន់គឺ សេចក្ដីយល់ឃើញខុសនោះ ឱ្យបានជាត្រឹមត្រូវឡើងវិញ ។

សទ្ធានេះឯងកាលណា បើតាំងមាំក្នុងសន្តានចិត្តរបស់បុគ្គលណាហើយ ក៏អាចញ៉ាំងវត្ថុបំណងឱ្យសំរេចទៅបាន ។ ដូចជាពុទ្ធភាសិតដែលព្រះអង្គ ទ្រង់ត្រាស់សំដែងថា : **សទ្ធា សាធុ បតិដ្ឋិតា** " សទ្ធាដែលតាំងមាំហើយអាចនឹងញ៉ាំងប្រយោជន៍ឱ្យសម្រេច " ។

ត្រង់ពាក្យថា សទ្ធាដែលតាំងមាំនោះមានពីរយ៉ាងគឺ , តាំងមាំមិនអាចត្រឡប់ប្រែប្រួលបាន , បានដល់អចលសទ្ធា ឬលោកុត្តរសទ្ធា ដូចសទ្ធារបស់ព្រះអរិយបុគ្គលទាំងឡាយ មានព្រះសោតាបន្នជាដើម , មានព្រះអរហន្តជាទីបំផុត , ចាត់ជាសទាដែលតាំងមាំល្អហើយ ១ , សទ្ធាដែលតាំងហើយត្រឡប់ប្រែប្រួលទៅវិញ បាននោះ បានដល់ចលសទ្ធា ឬលោកិយសទ្ធា ដូចសទ្ធារបស់បុថុជ្ជននេះឯង មិនចាត់ជាតាំងមាំល្អហើយ ១ , សទ្ធារបស់ព្រះអរិយបុគ្គលដែលចាត់ថាតាមងមាំល្អនោះ ព្រោះលោកបានភពប្រសព្វនឹង សន្ទិដ្ឋិកផលដែលពិត គឺបានសម្រេចដល់សោតាបត្តិផល ហើយទើបបានមានសេចក្ដីជឿមាំក្នុងធម៌ ដែលនឹងអាចធ្វើឱ្យបានសម្រេចធម៌ ពិសេសខាងលើឡើងតទៅទៀត មានសកទាគាមិមគ្គ រហូតដល់បានសម្រេចព្រះអរហត្តផលមិនត្រឡប់ប្រែប្រួលវិញ , ព្រោះហេតុនោះបានជាលោកចាត់ថាជាសទ្ធាបានតាំងមាំល្អហើយ ។ ចំណែក ខាងសទ្ធារបស់បុថុជ្ជន ដែលមិនចាត់ថាតាំងមាំល្អហើយនោះព្រោះនៅមិនបាន ភពប្រសព្វនឹងសទ្ទិដ្ឋិកផលដែលពិតនៅឡើយ គ្រាន់តែជួបប្រទះនឹងហេតុផល ដែលប្រៀបធៀបរបស់វត្ថុនោះ ៗខ្លះប៉ុណ្ណោះឯង បើទុកណាជានឹងតាំងមាំខ្លះនោះ ក៏ត្រឹមតែមួយពេលមួយស្របក់ប៉ុណ្ណោះយ៉ាងនេះក៏នៅតែរាប់ថាត្រឡប់ប្រែប្រួលវិញបាន , ព្រោះហេតុនោះបានជាលោកមិនចាត់ថាតាំងមាំល្អហើយ ។

សទ្ធាបើតាំងមាំក្នុងចិត្តរបស់បុគ្គលណាហើយ អាចធ្វើទានរបស់បុគ្គលនោះឱ្យសម្រេចបាន , ដូចមានអតីតនិទានតទៅនេះរឿងនេះមានសំដែងនៅក្នុងខទិរង្គារជាតក ឯកនិបាតថា :

កាលដែលកន្លងទៅហើយ ព្រះពោធិសត្វទ្រង់សោយព្រះជាតិជាកូនសេដ្ឋីនៅក្នុងនគរពារាណសី លុះឥតអំពីបិតាទៅ ព្រះបាទព្រហ្មទត្តបានតាំងបព្រះពោធិសត្វជាសេដ្ឋី ក្នុងនគរពារាណសី គ្រប់គ្រងសម្បត្តិជំនួសបិតា ។ ព្រះពោធិសត្វជាបុគ្គលមានសទ្ធាមុតមាំជឿកម្មផលច្បាស់លាស់ បានចំណាយទ្រព្យធ្វើសាលាទាន ៦ កន្លែង ហើយតែងបរិច្ចាគទានរក្សាឧបោសថសីលជានិច្ចពុំដែលខាន វេលាថ្ងៃមួយព្រះពោធិសត្វរៀបបរិភោគអាហារពេលព្រឹក ស្រាប់តែមានព្រះបច្ចេកពុទ្ធមួយព្រះអង្គទើបនឹងចេញចាកនិរោធសមាបត្តិ ហោះមកឈរទៀបទ្វារផ្ទះ ។ ពោធិសត្វក្រឡេកមើលទៅឃើញ ទើបប្រើបុរសម្នាក់ឱ្យទៅយកបាត្រពីលោកមកដាក់ចង្ហាន់ ។ គ្រានោះមារាធិរាជមកនិម្មិត ធ្វើជារណ្ដៅរងើកភ្លើងក្រហមរន្ទាលច្រាលឆ្អៅ ដូចជាអវិចីមហានរក ។ បុរសទៅយកបាត្រឃើញភ្លើងនោះហើយភិតភ័យណាស់ ត្រឡប់មកជំរាបព្រះពោធិសត្វវិញ ព្រះពោធិសត្វបានយល់ច្បាស់ថា មារនៅស្ថានវសវត្តីមកធ្វើឱ្យអន្តរាយទានផង ឱ្យអន្តរាយព្រះជន្មព្រះបច្ចេកពុទ្ធផង ទើបយកភាជន៍ដាក់ចង្ហាន់ពេញចេញអំពីផ្ទះទៅឈរក្បែររណ្ដៅភ្លើង ហើយទូលព្រះបច្ចេកពុទ្ធថា :

**កាមំ បតាមំ និរយំ ឧទ្ធំបាទោ អវំសិរោ**

**នានរិយំ ករិស្សាមិ ហន្ទ បិណ្ឌំ បដិគ្គហ** ។

ប្រែសេចក្ដីថា បពិត្រលោកម្ចាស់ដ៏ចំរើន បើទុកណាជាខ្ញុំធ្លាក់ដាំក្បាលចុះក្នុងរណ្ដៅភ្លើង ដូចជានរកនេះ ក៏ខ្ញុំមិនអាចថយក្រោយវិញដែរ សូមព្រះករុណាម្ចាស់ទទួលយកចង្ហាន់នេះចុះ ។

ព្រះពោធិសត្វនិយាយទូលព្រះបច្ចេកពុទ្ធដូច្នេះហើយ ក៏លោតចុះទៅក្នុងរណ្ដៅភ្លើងស្រាប់តែមានផ្កាឈូកដុះទ្រជើងយ៉ាងអស្ចារ្យ ព្រះពោធិសត្វបានយកចង្ហាន់ទៅដាក់បាត្រប្រគេនព្រះបច្ចេកពុទ្ធដោយសួស្ដី ។

ឯមារឃើញប្លែកអស្ចារ្យដូច្នេះហើយ ក៏ភ័យតក់ស្លុតវិនាសបាត់អំពីទីនោះទៅ ។

សសេចក្ដីមកប៉ុណ្ណេះ ដើម្បីបញ្ជាក់ឱ្យឃើញថា សទ្ធាកាលបើតាំងមាំល្អហើយ មិនអាចអ្នកណាមួយមកបំផ្លិចបំផ្លាញឱ្យវិនាសបានឡើយ ។ ដូចមាននិទានរឿងព្រះពោធិសត្វមកក្នុងទីនេះជាភស្តុតាងស្រាប់ហើយ ។

**ទី ២ : បញ្ញា** ការចេះដឹងស្គាល់កិច្ចការណ៍គ្រប់យ៉ាងគឺ តាំងអំពីគុណ , ទោស , បុណ្យបាប , អាក្រក់ល្អ , ស្គាល់ហេតុផលនៃសេចក្ដីសុខទុក្ខ , ចំរើន វិនាស , ទាំងបច្ចុប្បន្ននឹងក្នុងកាលជាអនាគត ទើបចាត់ថាជាទ្រព្យដ៏ប្រសើរទៅបាន ។

ព្រោះថា អ្នកប្រាជ្ញហៅបុគ្គល ដែលរស់នៅដោយប្រាជ្ញាថាជាអ្នករស់នៅប្រសើរបំផុត ។ ធម្មតាបុគ្គលក្នុងលោកច្រើនតែជាអ្នកត្រូវការដោយ អាយុយឺនយូរថាជារបស់ប្រសើរ តែថាកាលបើបានស្ដាប់ពាក្យប្រៀនប្រដៅ ក្នុង

ព្រះពុទ្ធសាសនាហើយ ក៏គង់ដឹងច្បាស់ថាជារបស់មិនវ្រសើរវិញ , ព្រោះជីវិតប្រព្រឹត្តទៅដោយសេចក្តីល្ងង់ខ្លៅ ដែលអ្នកប្រាជ្ញទាំងឡាយលោកមិនប្រាថ្នានោះមិនប្រសើរសោះឡើយ ។

ឯបុគ្គលដែលរស់នៅដោយឥតប្រាជ្ញា សូម្បីមានអាយុយឺនយូររហូតដល់ ១រយឆ្នាំក្តី ក៏ឥតមានប្រសើរអ្វីបន្តិចបន្តួច ត្រង់ការដែលគ្រាន់តែរស់នៅប៉ុណ្ណោះឡើយ , បើសិនណាជារស់នៅដោយប្រាជ្ញាវិញ កុំថាឡើយដល់ទៅមានអាយុ ១ រយឆ្នាំ សូម្បីមានអាយុតែត្រឹម ២-៣ ថ្ងៃប៉ុណ្ណោះក៏គង់ប្រសើរជាង, សមដូចជាពុទ្ធភាសិតក្នុងសហស្សវគ្គគម្ពីរធម្មបទថា :

**យោ ច វស្សសតំ ជីវេ ទុប្បញ្ញោ អសមាហិតោ**

**ឯកាហំ ជីវិតំ សេយ្យោ បញ្ញវន្តស្ស ឈាយិនោ ។**

សេចក្តីថា " បុគ្គលណាមានជីវិតរស់នៅ ១ រយឆ្នាំក្តី តែជាបុគ្គលអាប់ឥតប្រាជ្ញា ជាអ្នកមិនខ្ជាប់ខ្ជួន ( ក្នុងគុណសម្បត្តិណាមួយ )ជីវិតរស់នៅតែមួយថ្ងៃរបស់ដែលអ្នកមានប្រាជ្ញាមានសមាធិឈានតាំងនៅក្នុងខ្លួន ជីវិតរបស់អ្នកនោះប្រសើរជាង " ។ មួយវិញទៀតបុគ្គលជាគ្រហស្ថ ដែលជាអ្នកខ្វាក់ភ្នែកតែម្ខាងឬទាំងសងខាងក៏ពិតមែន តែគេអាចជម្រុះនូវសេចក្តីប្រតិបត្តិរបស់គ្រហស្ថ គឺក្រោកឡើងធ្វើការងារទទួលកាន់យកសរណគមន៏ ចាត់ចែងធ្វើទាន នឹងសមាទានសីល ៥ ឬ ឧបោសថសីលជាដើម ហើយរស់នៅ ជីវិតគ្រហស្ថនោះក៏ឈ្មោះថារស់នៅដោយប្រាជ្ញា ។

ចំណែកខាងបព្វជិត ត្រូវជម្រុះនូវសេចក្តី ប្រតិបត្តិរបស់បព្វជិត គឺធ្វើសីលឱ្យហ្មត់ចត់ ធ្វើចិត្តឱ្យផូរផង់ជាដើមដោយប្រាជ្ញា ជីវិតរបស់បព្វជិតនោះ ក៏ឈ្មោះថារស់នៅដោយប្រាជ្ញា ,ព្រោះហេតុនោះបានជាព្រះដ៏មានព្រះភាគសំដែងថា " ការរស់នៅដោយប្រាជ្ញា ទើបជាការរស់នៅប្រសើរបំផុត " ។

ឯបញ្ញានេះ ជាឈ្មោះសោភណចេកសិក តែងប្រព្រឹត្តទៅក្នុងអត្ថច្រើនប្រការ តែក្នុងទីនេះនឹងសូមចែកចេញជា ៣ ប្រការគឺ : ចិន្តាមយបញ្ញា ប្រាជ្ញាដែលសម្រេចដោយការគិត ១ , សុតាមយបញ្ញា ប្រាជ្ញាដែលសម្រេចដោយការស្តាប់ ១ , ភាវនាមយបញ្ញា ប្រាជ្ញាដែលសម្រេចដោយការភាវនាគឺចំរើនឱ្យមាន ឬអប់រំឱ្យកើតឡើង ១ ។

ប្រាជ្ញាដែលមានពោលមកហើយនោះ ចាត់ជា ២ ប្រការទៀតគឺ : លោកិយប្បញ្ញា ១ , លោកុត្តរប្បញ្ញា ១ ។

លោកិយប្បញ្ញា បើចែកតាមលំដាប់ភូមិមាន ៣ យ៉ាងគឺ ប្រាជ្ញាប្រព្រឹត្តទៅក្នុងកាមភូមិ ១ , ប្រព្រឹត្តទៅក្នុងរូបភូមិ ១ , ប្រព្រឹត្តទៅក្នុងអរូបភូមិ ១ ។

លោកុត្តរប្បញ្ញា បើហៅតាមប្រាជ្ញារបស់លោកអ្នកសម្រេចធម៌នោះៗ មាន ៩ យ៉ាង គឺ មគ្គ ៤ , ផល ៤ , និព្វាន ១ ។

បើចែកតាមជាន់ទាប នឹងជាន់ខ្ពស់ ក៏ចាត់ជា ២ យ៉ាងទៀតគឺ ប្រាជ្ញាឃើញសេចក្តីកើត នឹងសេចក្តីរលត់នៃសព្វវត្ថុទាំងពួង ដែលជារបស់ខាងក្រៅ

ចាត់ជាប្រាជ្ញាជាន់ទាប ប្រាជ្ញាឃើញនូវអរិយសច្ចៈ ទាំង ៤ ចាត់ជា ប្រាជ្ញាជាន់ខ្ពស់ ។

ប្រាជ្ញាអប់រំឱ្យកើតឱ្យចំរើនក្រៃលែងបានដោយហេតុច្រើនប្រការ មានការស្តាប់នឹងការប្រកបព្យាយាមជាដើម ។ សមនឹងពុទ្ធភាសិតថា **សុស្សូសំ លភតេ បញ្ញំ** " ស្តាប់ដោយល្អ រមែងបានប្រាជ្ញា " ។

បទមួយទៀតថា **យោគា វេ ជាយតេ ភូរិ** " ប្រាជ្ញាតែងកើតឡើងព្រោះប្រកបសេចក្តីព្យាយាម " ។ បទមួយទៀតថា **សុខា បញ្ញា បដិលាភោ** "ការបាននូវប្រាជ្ញា ជាហេតុនាំឱ្យកើតនូវសេចក្តីសុខ " នឹងបទថា **បញ្ញាយ បរិសុជ្ឈតិ** សត្វបរិសុទ្ធបានដោយសារប្រាជ្ញា , ប្រាជ្ញាក្នុងទីនេះព្រះលោកនាថជាម្ចាស់ទ្រង់ត្រាស់ថាព្រះអានាគាមិបុគ្គល បានញ៉ាំងប្រាជ្ញាដ៏សម្បយុត្តដោយមគ្គជាគំរប់ ៤ ឱ្យបរិសុទ្ធដោយចំណែកមួយ ដោយញាណដ៏បរិសុទ្ធដែលប្រាសចាកមន្ទិល គឺ កាម ហើយបានលះបង់នូវមន្ទិលដ៏ល្អិតពោលគឺអវិជ្ជា ដែលព្រះអនាគាមិមគ្គមិនទាន់លះបង់បាននោះ , ព្រោះហេតុដូច្នេះបានជាព្រះទ្រង់ប្រកាសនូវអរហត្តមគ្គផង , នូវ អរហត្តផលផង ដែលជាគ្រឿងឆ្លងចាកនូវអវិជ្ជា ។ នឹងបទមួយទៀតថា **នត្ថិ បញ្ញាសមា អាភា** " ពន្លឺអ្វីមួយស្មើដោយពន្លឺប្រាជ្ញាមិនមានឡើយ " ។

ក៏ធម្មតាពន្លឺ ក្នុងលោកមាន ៣ យ៉ាង គឺ ពន្លឺព្រះអាទិត្យ ១ , ពន្លឺព្រះច័ន្ទ១ , ពន្លឺភ្លើង ១ , បើរាប់ប្រាជ្ញាជាពន្លឺមួយទៀតក៏ត្រូវជាពន្លឺក្នុងលោកមាន ៤ យ៉ាង , តែត្រង់ពន្លឺទី ៤ ផ្សេងគ្នាដោយនិពន្ធគាថាដូច្នេះ

**ចត្តារោ លោកេ បជ្ជោតា បញ្ចេត្ថ ន វិជ្ជតិ**
**ទិវា តបតិ អាទិច្ចោ រត្តិមាភាតិ ចន្ទិមា**
**អថ អគ្គិ ទិវារត្តិំ តត្ថ តត្ថ បភាសតិ**
**សម្ពុទ្ធោ តបតំ សេដ្ឋោ ឯសា អាភា អនុត្តរា ។**

ពន្លឺក្នុងលោកសន្និវាសនេះមានតែ ៤ គត់ មិនដែលមានដល់ទៅ ៥ ឡើយ ពន្លឺព្រះអាទិត្យបំភ្លឺបានតែក្នុងវេលាថ្ងៃ ពន្លឺព្រះចន្ទបំភ្លឺបានតែវេល្បាយប់ ពន្លឺភ្លើងបំភ្លឺបានតែក្នុងទីនោះៗ ទោះបីយប់ថ្ងៃតាមគួរដល់ការប្រកប ឯព្រះសម្មាសម្ពុទ្ធព្រះអង្គជាពន្លឺប្រសើរបំផុតជាងពន្លឺដ៏សេស មានពន្លឺព្រះអាទិត្យ ជាដើមដែលជាអ្នកបំភ្លឺនោះ ៗ ព្រោះថា ព្រះសម្មាសម្ពុទ្ធជាម្ចាស់ក្តី ឬប្រាជ្ញានោះក្តីក៏ជាពាក្យរួមចុះជាមួយគ្នា ប្លែកតែពាក្យដែលពោលថា ព្រះសម្មាសម្ពុទ្ធនុ៎ះជាបុគ្គលាធិដ្ឋានទេសនា ឯប្រាជ្ញានៅជាធម្មាធិដ្ឋានទេសនាប៉ុណ្ណោះ ។

ក៏បណ្តាពន្លឺទាំង ៤ នោះ បើនឹងធៀបគ្នាសម្រាប់ឱ្យជាប្រយោជន៍ពិតប្រាកដដល់សត្វអ្នកត្រូវការប្រាថ្នាយកសេចក្តីសុខ តែម្យ៉ាងនោះ ក៏ត្រូវលើកថាប្រាជ្ញាជាប្រយោជន៍ពិតប្រាកដមែន ។

ធមិទាំងពីរប្រការ គឺ **សទ្ធា** នឹង **បញ្ញា** នេះ បានជាឱ្យឈ្មោះថា ជាទ្រព្យដ៏ប្រសើរ បំផុតនោះព្រោះថាជារបស់ឋិតថេរចិរកាល មិនចេះវិនាស មិនចេះអន្តរាយ ទោះបីភ្លើងក៏មិនឆេះ ចោរលួចក៏មិនបាន ទុកជា អន្តយ ដោយហេតុឯណាមួយក៏មិនអាចមកបំផ្លាញ មិនអាចធ្វើឱ្យខាតបង់បានឡើយ ។

បុរស ស្ត្រីឯណា មានទ្រព្យទាំងពីរប្រការ ដូចបាបរៀបរាប់ដោយ សង្ខេបមកនេះ បុរស ស្ត្រី នោះ លោកអ្នកប្រាជ្ញទាំងឡាយ មានព្រះពុទ្ធ ជាដើម ព្រះអង្គពោលថាមិនមែនជាអ្នកទ័លក្រឡើយ គឺឈ្មោះថាជាអ្នកមាន ទ្រព្យសម្បត្តិដ៏ស្តុកស្តម្ភ មាំមួនដោយពិត ទាំងការរស់នៅ របស់បុរស ស្ត្រី នោះទៀតមិនឈ្មោះថា រស់នៅឥតអំពើឡើយ ។

មនុស្សសត្វដែលគ្រាន់តែរស់នៅតាមធម្មតា ប៉ុន្តែបើគ្មានទ្រព្យទាមងពីរ ប្រការ នេះទ្រព្យណាមួយទុកក្នុងខ្លួនទេ ការរស់នៅនោះក៏ឈ្មោះថារស់នៅពុំ មានប្រយោជន៍ឡើយ ។

ចំណែកិធមិទាំងពីរប្រការ គឺ សទ្ធា នឹង បញ្ញា ដែលបានអធិប្បាយមក ក្នុងទីនេះ មិនបានជាវិត្ថារន័យដោយសេចក្តីពិស្តារវែងឆ្ងាយប៉ុន្មានទេ តែសន្មតិ ថាចប់ដោយសង្ខេបត្រឹមប៉ុណ្ណេះឯង ។

**( សួស្តី )**